ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី លី ច័ន្ទតុលា

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ខួនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូច ចន្ថា
១២-មេធាវី ហុង គឹមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង ស៊ុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ណុប គុណធុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា


លេខ ៣៤៤ /សសគម/២១

# សេចក្តីសម្រេច
# ស្តីពី
# បែបបទនៃការប្រឡងវិញ្ញាសាសរសេរសម្រាប់បេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- បានឃើញសេចក្តីសម្រេចលេខ ១១៦/សសគម/២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី

## ស ម្រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .. គោលបំណង

សេចក្តីសម្រេចនេះមានគោលបំណងត្រួតពិនិត្យសមត្ថភាពរបស់បេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី តាមរយៈការកំណត់អំពីបែបបទនៃការប្រឡងលើវិញ្ញាសាសរសេរ។


អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខៈ ១៥៨៧, ទូរស័ព្ទៈ ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

**ប្រការ២ .. វិសាលភាព**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះបេក្ខជនដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី សម្រាប់ការប្រឡងលើវិញ្ញាសាសរសេរ។

## ជំពូកទី២
## គណៈមេប្រយោគ

**ប្រការ៣ .. សមាសភាពរបស់គណៈមេប្រយោគ**

គណៈមេប្រយោគមានសមាសភាព ២(ពីរ)រូបគឺ៖

១.ប្រធានគណៈមេធាវី ប្រធានគណៈមេប្រយោគ

២.តំណាងអគ្គលេខាធិការដ្ឋានគណៈមេធាវី សមាជិកគណៈមេប្រយោគ។

សមាជិកគណៈមេប្រយោគ ត្រូវតែងតាំងដោយប្រធានគណៈមេប្រយោគ តាមសំណើរបស់អគ្គលេខាធិការគណៈមេធាវី។

តាមការចាំបាច់ ប្រធានគណៈមេប្រយោគអាចចាត់តាំងបុគ្គលិកគណៈមេធាវីម្នាក់ឬច្រើននាក់ឱ្យជួយដល់ការងារប្រឡងលើវិញ្ញាសាសរសេរនេះបាន។

**ប្រការ៤ .. ភារកិច្ចរបស់គណៈមេប្រយោគ**

គណៈមេប្រយោគមានភារកិច្ចដូចខាងក្រោម៖

- កំណត់កាលបរិច្ឆេទប្រឡង ទីកន្លែងប្រឡង និងចំនួនបេក្ខជនដែលត្រូវមកប្រឡង
- ចេញវិញ្ញាសាសម្រាប់ប្រឡង
- ត្រួតពិនិត្យការប្រឡង
- ដាក់ទណ្ឌកម្មលើបេក្ខជនណាមួយដែលរំលោភលើបទបញ្ជានៃការប្រឡង
- ចាត់តាំងគ្រូកំណែលើវិញ្ញាសាប្រឡងរបស់បេក្ខជន
- ប្រកាសលទ្ធផលនៃការប្រឡង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

គណៈមេប្រយោគមានសិទ្ធិប្រើត្រា លេខលិខិតរដ្ឋបាល និងធនធានផ្សេងៗរបស់គណៈមេធាវី ដើម្បីសម្រួលដល់ការប្រឡង។

## ជំពូកទី៣
## បែបបទនៃការប្រឡង

**ប្រការ៥ .. រយៈពេលនិងមុខវិជ្ជាប្រឡង**

រយៈពេលនៃការប្រឡងមានចំនួន៣ (បី)ម៉ោង លើមុខវិជ្ជាដែលត្រូវប្រឡងចំនួន៣(បី)គឺ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦ .. ការជូនដំណឹងអំពីការប្រឡង**

ប្រធានគណៈមេប្រយោគត្រូវជូនដំណឹងដល់បេក្ខជនដែលត្រូវចូលរួមប្រឡងអំពី ម៉ោង ថ្ងៃ និងទីកន្លែងប្រឡងឱ្យបានយ៉ាងតិច ១(មួយ)សប្តាហ៍មុនថ្ងៃប្រឡង។ ការជូនដំណឹងនេះអាចធ្វើជាលាយលក្ខណ៍អក្សរផ្ញើជូនបេក្ខជនផ្ទាល់ដៃឬតាមរយៈទូរស័ព្ទទៅបេក្ខជនម្នាក់ៗ ដោយមានបញ្ជាក់តាមការផ្ញើចូលប្រព័ន្ធទំនាក់ទំនងសង្គមផ្ទាល់ខ្លួនរបស់បេក្ខជននោះ។

ប្រធានគណៈមេប្រយោគត្រូវចាត់ឱ្យបិទបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡង នៅក្នុងបញ្ជរព័ត៌មានរបស់គណៈមេធាវីនិងអាចផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយរបស់គណៈមេធាវីបាន។

**ប្រការ៧ .. ការចេញវិញ្ញាសាប្រឡង**

ប្រធានគណៈមេប្រយោគជាអ្នកចេញវិញ្ញាសាសម្រាប់ការប្រឡងវិញ្ញាសាសរសេរម្ដងៗ។ វិញ្ញាសាសរសេរត្រូវចែកជា២(ពីរ)គឺ វិញ្ញាសាលើមុខវិជ្ជាក្រមនីតិវិធីព្រហ្មទណ្ឌនិងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់រយៈពេល ១:៣០(មួយម៉ោងនិងសាមសិបនាទី) និងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនិងក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល១:៣០(មួយម៉ោងនិងសាមសិបនាទី)។

**ប្រការ៨ .. ភារកិច្ចរបស់បេក្ខជនដែលត្រូវប្រឡង**

បេក្ខជនប្រឡងត្រូវអនុវត្តតាមបទបញ្ជាប្រឡងដូចបានកំណត់ក្នុងជំពូកទី៤ នៃសេចក្ដីសម្រេចនេះនិងអនុវត្តតាមការណែនាំរបស់គណៈមេប្រយោគឱ្យបានម៉ឺងម៉ាត់។

បេក្ខជនដែលមិនគោរពតាមបទបញ្ជាប្រឡងឬការណែនាំរបស់គណៈមេប្រយោគ ត្រូវទទួលទណ្ឌកម្មវិន័យតាមការសម្រេចរបស់គណៈមេប្រយោគ។

**ប្រការ៩ .. ការធ្វើកំណែលើវិញ្ញាសាប្រឡង**

ប្រធានគណៈមេប្រយោគនិងគ្រូកំណែជាអ្នកកំណត់អត្រាកំណែ។ គ្រូកំណែជាអ្នកធ្វើកំណែលើវិញ្ញាសាប្រឡងរបស់បេក្ខជន ដោយកំណត់ពិន្ទុ២០/២០។

**ប្រការ១០ .. លទ្ធផលប្រឡង**

លទ្ធផលប្រឡងត្រូវទទួលស្គាល់ដោយគណៈមេប្រយោគ។ លទ្ធផលនេះទុកសម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិចារណាជាមូលដ្ឋាន នៅពេលពិនិត្យនិងសម្រេចលើការអនុញ្ញាតឱ្យបេក្ខជនណាមួយចូលប្រកបវិជ្ជាជីវៈមេធាវី។

## ជំពូកទី៤
## បទបញ្ជាប្រឡង

**ប្រការ១១ .. បទបញ្ជា**

**បេក្ខជនប្រឡងត្រូវ៖**

១.យកមកជាមួយនូវអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន ដើម្បីបង្ហាញគណៈមេប្រយោគ។

២.មកដល់កន្លែងប្រឡងឱ្យបានមុនពេលដំណើរការប្រឡង។

៣.ស្លៀកពាក់ឯកសណ្ឋានសមរម្យ។

៤.ប្រកាន់អាកប្បកិរិយាសមរម្យ ថ្លៃថ្នូរ។

៥.គោរពការណែនាំរបស់គណៈមេប្រយោគ។

៦.បំពេញក្បាលសន្លឹកកិច្ចការប្រឡងឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់តាមការណែនាំរបស់គណៈមេប្រយោគ។

៧.សរសេរលើសន្លឹកកិច្ចការសម្រាប់ធ្វើវិញ្ញាសាសរសេរដែលចែកជូនដោយគណៈមេប្រយោគ។

៨.ប្រើប្រាស់សន្លឹកកិច្ចការទាំងមូល ដើម្បីតាក់តែងចម្លើយ។

៩.ប្រើក្រដាសព្រាងដែលមានត្រាគណៈមេធាវីដែលរៀបចំដោយគណៈមេប្រយោគ និងត្រូវចុះលេខតុរបស់បេក្ខជននៅចុងសន្លឹក។

១០.សុំការអនុញ្ញាតពីគណៈមេប្រយោគ នៅពេលមានធុរៈចាំបាច់ឬទៅបន្ទប់ទឹក។

១១.ប្រគល់សន្លឹកកិច្ចការជូនគណៈមេប្រយោគវិញនៅពេលដល់ម៉ោងកំណត់ ទោះបីជាកិច្ចការនោះធ្វើរួចរាល់ឬមិនទាន់រួចរាល់ក្តី។

១២.រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងពេលប្រឡង និងគោរពឱ្យបានត្រឹមត្រូវតាមការណែនាំផ្សេងទៀតដែលត្រូវអនុវត្តក្នុងពេលប្រឡង។

**បេក្ខជនប្រឡងមិនត្រូវ៖**

១.យកសំណៅឯកសារច្បាប់ សៀវភៅច្បាប់ ឯកសារ ឬកំណត់ត្រាផ្សេងៗចូលបន្ទប់ប្រឡងឡើយ លើកលែងតែវិញ្ញាសាបានកំណត់ឱ្យបេក្ខជនមើលឯកសារបាន។

២.យកសម្ភារដទៃទៀតដូចជា អាវុធជាតិផ្ទុះ ទូរស័ព្ទ វិទ្យុទាក់ទងផ្សេងៗ កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិច ឬឧបករណ៍ផ្សេងៗគ្រប់ប្រភេទ ចូលបន្ទប់ប្រឡងឡើយ។ គណៈមេប្រយោគមានសិទ្ធិដកហូតនូវរាល់សម្ភារនិងឧបករណ៍ទាំងនោះ **<u>ហើយមិនទទួលខុសត្រូវចំពោះការខូចខាតឬការបាត់បង់ឡើយ</u>**។

៣.ចូលបន្ទប់ប្រឡងមុនពេលគណៈមេប្រយោគហៅឈ្មោះឱ្យចូល។

៤.ប្តូរសន្លឹកកិច្ចការ ឬក្រដាសព្រាងឱ្យគ្នាទៅវិញទៅមក ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា ឬដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួន បង្កឱ្យអ្នកដទៃមើល ឬឆក់យកបានឡើយ។

៥.ឱ្យអ្នកដទៃមកប្រឡងជំនួស ឬមកប្រឡងជំនួសអ្នកដទៃឡើយ។

៦.ចូលបន្ទប់ប្រឡងក្រោយ ១៥ នាទី បន្ទាប់ពីការចែកវិញ្ញាសា។

៧.ចុះហត្ថលេខា ឬហត្ថលេខាសង្ខេប ឬធ្វើសញ្ញាសម្គាល់ណាមួយលើសន្លឹកកិច្ចការខុសពីសេចក្តីណែនាំរបស់គណៈមេប្រយោគ។

៨.ពិភាក្សា ឆ្លើយឆ្លង លួចចម្លង ឱ្យគេចម្លង និងទទួលព័ត៌មានពីខាងក្រៅ។

៩.សរសេរលើសន្លឹកកិច្ចការណាដែលគ្មានហត្ថលេខារបស់គណៈមេប្រយោគ។

១០.សរសេររំលងបន្ទាត់ ឬក្រោមបន្ទាត់ ឬមិនជាប់បន្ទាត់ នៅលើសន្លឹកកិច្ចការ។

១១.សរសេររំលងទំព័រ ឬទុកទំព័រសន្លឹកកិច្ចការណាមួយឱ្យនៅទំនេរ។

១២.គូសបន្ទាត់ពុះសន្លឹកកិច្ចការជាពីរ។

**ប្រការ១២ .. ទណ្ឌកម្ម**

**ត្រូវបានកំណត់ឱ្យពិន្ទុសូន្យលើសន្លឹកកិច្ចការរបស់បេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖**

១.ដើរចុះដើរឡើងចេញពីកន្លែងអង្គុយ ដោយគ្មានការអនុញ្ញាតពីគណៈមេប្រយោគ។

២.ហែកសន្លឹកកិច្ចការ ឬមិនព្រមប្រគល់សន្លឹកកិច្ចការជូនគណៈមេប្រយោគ។

៣.ផ្លាស់កន្លែងអង្គុយ ឬលុបលេខតុពីកន្លែងដែលបានកំណត់ ឬទៅសរសេរលេខតុរបស់ខ្លួននៅកន្លែងផ្សេង ដោយគ្មានការអនុញ្ញាតពីគណៈមេប្រយោគ។

៤.ឱ្យ ឬទទួលសន្លឹកកិច្ចការ ឬសំណៅក្រដាសព្រាងរបស់ខ្លួនទៅ ឬពីអ្នកដទៃចម្លង ឬផ្ទៀងផ្ទាត់ចម្លើយ។

៥.ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន ឬជួយសរសេរលើសន្លឹកកិច្ចការរបស់អ្នកដទៃ។
៦.បន្លំមកប្រឡងជំនួសអ្នកដទៃ ឬឱ្យអ្នកដទៃមកប្រឡងជំនួស។
៧.ធ្វើសញ្ញាសម្គាល់ ឬគំនូសសម្គាល់លើសន្លឹកកិច្ចការប្រឡង។
៨.ប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទង កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ ដែលប្រើប្រាស់សម្រាប់ទំនាក់ទំនងក្នុងការធ្វើវិញ្ញាសាសរសេរ។

**ហាមមិនឱ្យប្រឡង និងត្រូវបណ្តេញចេញពីបន្ទប់ប្រឡង ឬលទ្ធផលដែលប្រឡងជាប់នឹងត្រូវបដិសេធចំពោះបេក្ខជនដែលមានសកម្មភាពដូចខាងក្រោម ៖**

១.បោះវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកឯកសារ ឬក្លែងបន្លំឯកសារ ឬយកសំណៅចម្លើយពាក់ព័ន្ធនឹងវិញ្ញាសាចូលក្នុងបន្ទប់ប្រឡងក្នុងពេលកំពុងធ្វើវិញ្ញាសា។
២.បង្កជម្លោះនៅក្នុងបន្ទប់ប្រឡង ឬគំរាមកំហែងលើបេក្ខជនដទៃ។
៣.ដណ្តើមយកសន្លឹកកិច្ចការរបស់អ្នកដទៃមកចម្លង ឬហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ ឬយកសន្លឹកកិច្ចការអ្នកដទៃមកធ្វើជាសន្លឹកកិច្ចការរបស់ខ្លួន។
៤.យកអាវុធជាតិផ្ទុះចូលក្នុងបន្ទប់ប្រឡង។
៥.ធ្វើឱ្យខូចខាតសម្ភារក្នុងបន្ទប់ប្រឡងដោយចេតនា។
៦.បង្កបាតុភាពជាពាក្យសំដី ជាកាយវិការ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬរាងកាយ ឬគំរាមកំហែងដល់គណៈកម្មការរៀបចំការប្រឡង ឬអ្នកមានសមត្ថកិច្ចត្រួតពិនិត្យការប្រឡង។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៣ .. និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .. ការអនុវត្ត**

អគ្គលេខាធិការគណៈមេធាវី ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ៧ បញ្ចមី ១ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២១
**ប្រធានគណៈមេធាវី**

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

មេធាវី លី_ចន្ទតុលា

*ចម្លងជូន:*
-ក្រុមប្រឹក្សាគណៈមេធាវី
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ